# FATHER FRIENDLY LONG BEACH

## Why Dad Matters

## ប្រតិបត្តិ របស់បុគ្គលិក

1) **សូមសួរ អំពីឪពុក ក្នុងគ្រប់ដំណាក់កាលទាំងអស់ នៃទំនាក់ទំនង ជាមួយអតិថិជន/គ្រួសារ ហើយធានាថា លោកអ្នកប្រមូលព័ត៌មាន បានស្មើៗ គ្នា អំពីម្តាយ និងឪពុក ។**

   *ឧទាហរណ៍ ៖ តើកូនៗ មានចំណាយពេល នៅជាមួយឪពុក របស់ពួកគេ ឬ តួអង្គ ពាក់ព័ន្ធនឹងឪពុក ដែរឬទេ ?*
   *ឧទាហរណ៍ ៖ តើមានឱកាសប្រមូល មតិយោបល់ របស់ឪពុក ក្នុងសេចក្តីសម្រេចនានា ពាក់ព័ន្ធនឹងកុមារ ដែរឬទេ ?*
   *ឧទាហរណ៍ ៖ តើមាន លេខទូរសព្ទ/អាសយដ្ឋាន ដែលយើងអាចប្រើ ដើម្បីទំនាក់ទំនង ទៅឪពុក បានដែរឬទេ ? (ដោយគ្រាន់តែសួរ, ប្រសិនបើឪពុក-ម្តាយ ឬ អាណាព្យាបាល បានឆ្លើយតប លក្ខណៈវិជ្ជមាន ចំពោះសំណួរណាមួយ នៃសំណួរទាំងពីរ ខាងលើនេះ ឬអត់នោះ ។)*
   *ឧទាហរណ៍ ៖ តើទម្រង់បែបបទជ្រើសចូលបម្រើការងារ សួរសំណួរ អំពីឪពុក និងម្តាយ បានស្មើៗ គ្នា ដែរឬទេ ? បើមិនស្មើគ្នាទេ, តើខ្ញុំអាចធានាថា ខ្ញុំ សួរសំណួរ អំពីម្តាយ និងឪពុក ឱ្យបានស្មើៗ គ្នា បានដោយរបៀបណាដែរ ?*

2) **ត្រូវប្រាកដថា បុគ្គលិកទាំងអស់ យល់ច្បាស់ ហើយស្វាគមន៍ ឪពុក/បុរស ដែលបានចូលមកក្នុងគ្រឹះស្ថាន ហើយយល់ដឹង ពីភាពលំអៀង លក្ខណៈបុគ្គល របស់ពួកគេ អំពីបុរស/ឪពុក ។**

   *ឧទាហរណ៍ ៖ ចាត់វិធានការបន្ថែមទៀត ដើម្បីស្វាគមន៍ឪពុកនានា ដែលបានចូលមក ក្នុងគ្រឹះស្ថាន របស់លោកអ្នក ។ សួរស្តី ។ សូមស្វាគមន៍ មកកាន់ ____ ។ សូមអរគុណលោកអ្នក ដែលបានអញ្ជើញមក ថ្ងៃនេះ ។ តើខ្ញុំអាចជួយលោកអ្នក បានដោយរបៀបណាដែរ ?*
   *ឧទាហរណ៍ ៖ លើកសរសើរ អំពីទំនាក់ទំនង រវាងឪពុក និងកូន ។ ទារក មានការសប្បាយរីករាយ ហើយសើចលេង ជាមួយលោក ប៉ា ។*

3) **ស្វែងរក ឱកាសបណ្តុះបណ្តាល ដើម្បីស្វែងយល់ ឱ្យកាន់តែប្រសើរឡើង អំពីឧបសគ្គ ផ្នែកវប្បធម៌ និងផ្នែកគ្រួសារ ចំពោះការចូលរួម ពីឪពុក នៅក្នុងជីវិត របស់កូនៗ ។**

*ឧទាហរណ៍ ៖ តើលោកអ្នកធ្លាប់ទទួលបាន ការបណ្តុះបណ្តាល ដើម្បីផ្តល់សេវាភាសា ដែលមានលក្ខណៈមិនរើសអើង ហើយមិនប្រកាន់ ចំពោះបុរស/ឪពុក ដែរឬទេ ?*
*ឧទាហរណ៍ ៖ តើមានគម្លាតចំណេះដឹងអ្វីខ្លះ ដែលលោកអ្នកអាចមាន ចំពោះការយល់ដឹង អំពីឪពុក ដែលលោកអ្នកបម្រើសេវាជូន ?*

4) **លើកទឹកចិត្ត ឱ្យមានការចូលរួម ពីឪពុក-ម្តាយ ដែលមិននៅមើលថែកូន នៅក្នុងសកម្មភាពនានា របស់គ្រឹះស្ថាន ។**

*ឧទាហរណ៍ ៖ យើងយល់ដឹងថា នាពេលបច្ចុប្បន្ន ឪពុកមិនរស់នៅ ជាមួយលោកអ្នក និងកូន នោះទេ ។ តើមានមធ្យោបាយ ដែលយើងអាច ជំរុញឱ្យមានការចូលរួម ពីឪពុក បានដែរឬទេ ? តាមតែអាចធ្វើទៅបាន គ្រឹះស្ថានរបស់យើងព្យាយាមជំរុញឱ្យមានការចូលរួម ពីឪពុក ដោយសារវាមានអត្ថប្រយោជន៍ ជាសារវន្ត ចំពោះកុមារ ។ តើយើងអាចផ្សព្វផ្សាយ ឱ្យគាត់ដឹង បានដែរឬទេ ?*
*ឧទាហរណ៍ ៖ ប្រសិនបើយើងទុកព័ត៌មានខ្លះ អំពីកម្មវិធី/សេវា របស់យើង ឱ្យលោកអ្នក, តើលោកអ្នកអ្នកអាចផ្តល់ព័ត៌មាននេះ ទៅឪពុកនាន បានដែរឬទេ ? ឬ តើលោកអ្នកអាចទុកកិច្ចការនេះ ឱ្យអ្នកផ្សេងទៀត ដែលអាចផ្តល់ព័ត៌មាននេះ ទៅឪពុក ដែរឬទេ ?*

5) **កំណត់រកធនធានជាក់លាក់របស់ឪពុកនៅក្នុងសហគមន៍។**

*ឧទាហរណ៍ ៖ តើខ្ញុំមានស្គាល់ អ្នកផ្តល់សេវា នៅក្នុងសហគមន៍ ដែលមានឯកទេស ខាងប្រតិបត្តិផ្ទាល់ (ដូចជា ការផ្តល់ប្រឹក្សា និង ការថែទាំវេជ្ជសាស្ត្រ) ជាមួយឪពុកនានា ដែរឬទេ ?*
*ឧទាហរណ៍ ៖ តើខ្ញុំអាចកសាងទំនាក់ទំនង ជាមួយដៃគូសហគមន៍នានា ដែលផ្តល់សេវាគាំទ្រ (ដូចជា សេវាការងារ និងសេវាផ្នែកច្បាប់) ដល់ឪពុក បានដោយរបៀបណាដែរ ?*

ខែមីនា ឆ្នាំ 2019